

ព្រះបាទសូរ្យវរ្ម័នទី២

គយគន់ចម្លាក់លើជញ្ជាំង បាទាស្ងើរគាំងចិត្តភ្ញាំងភ្ញឹក
ក្បួនព្យូហ៍យាត្រាយ៉ាងអឹកធឹក ឱ្យខ្ញុំនឹកស្ងើចពន់ពេកក្រៃ។
គួរកោតជាងគេគឺព្រះបាទ នរនាថសូរ្យវរ្ម័នថ្ងៃ
ទ្រង់គង់យ៉ាងហ៊ំលើដំរី អាវុធនៅដៃច្រើនប្រការ។
រូបមួយទ្រង់កាន់ដាវជាញជ័យ ស័ក្តិសមប្រពៃជនហានក្លា
រូបមួយកាន់ធ្នូនិងសរថ្វា ហៅសែនសង្ហាពេកកន្ទង់។
រូបមួយនុះទ្រង់កាន់ផ្គាក់ រូបមួយកាន់ដាក់លំពែងផ្គង
ឯរូបមួយនោះកាន់ដំបង រូបមួយទៀតហោងកាំបិតស្នៀត។
ឃើញស្ដេចទ្រង់ឫទ្ធិឥទ្ធិពលក្លា សត្រូវឯណានឹងហ៊ានបៀត?
ខ្ញុំគ្រាន់តែនឹកបន្តទៀត ស្ដីទៅសូមញាតិកុំខឹងអី។
តើព្រះសូរ្យៈដាក់ខ្លាំងក្លា ឬជាងរចនាការកែច្នៃ
ដើម្បីលើកយសខ្ពស់ប្រពៃ ថ្វាយម្ចាស់ផែនដីនៃយើងនេះ?

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី

រូបភាពចម្លាក់លើជញ្ជាំងប្រាសាទអង្គរវត្ត - របៀងខាងត្បូង